# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ១១៧ ប្រក

ថ្ងៃ អង្គារ ៨ កើត ខែ អាសាឍ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១៩

# ប្រកាស
## ស្តីពី
## ការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ ភ្នាក់ងារទេសចរណ៍ និងសាខា

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងប្រកាសលេខ១៤៥ ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍។

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះមានគោលបំណងពង្រឹងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព និងលើកកម្ពស់គុណភាពសេវាកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ដើម្បីបង្កើនការទាក់ទាញទេសចរជាតិនិងអន្តរជាតិ។

**ប្រការ២ ._**

ប្រកាសនេះមានគោលដៅកំណត់អំពីវិធាន និងយន្តការគ្រប់គ្រងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងឡាយដែលធ្វើអាជីវកម្មកក់ ឬលក់សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ឬរៀបចំនិងបង្កើតខ្សែទស្សនកិច្ចជូនភ្ញៀវទេសចរណ៍ក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ ._**

បច្ចេកស័ព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះមានន័យ ដូចខាងក្រោម ៖

- **បុគ្គល** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល
- **ប្រតិបត្តិករទេសចរណ៍** សំដៅដល់បុគ្គលដែលប្រតិបត្តិ ប្រកបអាជីព ឬធ្វើអាជីវកម្មលើសេវា-កម្មទេសចរណ៍
- **សាខា** សំដៅដល់ការិយាល័យតំណាងឱ្យការីទេសចរណ៍ឬភ្នាក់ងារទេសចរណ៍ ដែលធ្វើសកម្មភាពក្នុងដែនកំណត់ដែលមានការយល់ព្រមតាមកិច្ចសន្យា
- **ការីទេសចរណ៍** សំដៅដល់បុគ្គលដែលរៀបចំនិងលក់ខ្សែទស្សនកិច្ច ព្រមទាំងប្រមូលផ្តុំសេវាកម្មទេសចរណ៍ផ្សេងៗទៀតសម្រាប់លក់ដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារទេសចរណ៍ ឬភាគីផ្សេងទៀតក្នុងកិច្ចសន្យា
- **ភ្នាក់ងារទេសចរណ៍** សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀតរាប់បញ្ចូលខ្សែទស្សនកិច្ចដែលបង្កើតឡើងដោយការី-ទេសចរណ៍ផងដែរ។
- **ភ្នាក់ងារទេសចរណ៍ក្នុងស្រុក** (Domestic Travel Agent) សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ជាលក្ខណៈគ្រួសារ ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មផ្សេងៗទៀតរាប់បញ្ចូលខ្សែទស្សនកិច្ច ដែលបង្កើតឡើងដោយការីទេសចរណ៍ដែលនាំភ្ញៀវកម្សាន្តក្នុងព្រះរាជា-ណាចក្រកម្ពុជា។

**ប្រការ៥ ._**

ការីទេសចរណ៍ (Tour Operators) ត្រូវបានបែងចែកជា០៣(បី)ប្រភេទ ដូចតទៅ៖

- **ការីទេសចរណ៍ដែលនាំភ្ញៀវចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា** (Inbound Tour Operators) សំដៅដល់បុគ្គលដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវនៅក្រៅប្រទេសចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា
- **ការីទេសចរណ៍ដែលនាំភ្ញៀវទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា** (Outbound Tour Operators) សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវដែលមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា

- **ការីទេសចរណ៍ដែលនាំភ្ញៀវកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Domestic Tour Operators)** សំដៅដល់បុគ្គលសញ្ជាតិខ្មែរដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

ភ្នាក់ងារទេសចរណ៍ (Travel Agent) ត្រូវបានចែកចេញជា០២(ពីរ)ប្រភេទ ដូចតទៅ៖

- **ភ្នាក់ងារទេសចរណ៍ (Travel Agent)** សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗរាប់បញ្ចូលខ្សែទស្សនកិច្ចដែលបង្កើតដោយការីទេសចរណ៍ផងដែរ
- **ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent)** សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ជាលក្ខណៈគ្រួសារ ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍និងសេវាកម្មផ្សេងៗទៀត រាប់បញ្ចូលខ្សែទស្សនកិច្ចដែលបង្កើតឡើងដោយការីទេសចរណ៍ដែលនាំភ្ញៀវកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៦ ._**

អាជ្ញាបណ្ណទេសចរណ៍ត្រូវបានផ្ដល់ទៅតាមប្រភេទអាជីវកម្មសម្រាប់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍រួមមាន៖

- អាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ដែលនាំភ្ញៀវចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Inbound Tour Operators)
- អាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ដែលនាំភ្ញៀវទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា (Outbound Tour Operators)
- អាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ដែលនាំភ្ញៀវកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Domestic Tour Operators)
- អាជ្ញាបណ្ណទេសចរណ៍សម្រាប់ភ្នាក់ងារទេសចរណ៍ (Travel Agent)
- អាជ្ញាបណ្ណទេសចរណ៍សម្រាប់ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent)។

**ប្រការ៧ ._**

លក្ខណៈវិនិច្ឆ័យនៃការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) ត្រូវបានកំណត់ ដូចខាងក្រោម៖

ក. បុគ្គលដែលមានសញ្ជាតិខ្មែរ

ខ. ធ្វើប្រតិបត្តិការអាជីវកម្មក្នុងដែនកំណត់មួយក្នុងតំបន់ ឬរាជធានីខេត្តដែលខ្លួនរស់នៅ

គ. ធ្វើអាជីវកម្មទេសចរណ៍ខ្នាតតូច ជាលក្ខណៈគ្រួសារដែលមិនជាប់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

ឃ. ទទួលផលរបរប្រចាំឆ្នាំមិនលើសពី៥០.០០០.០០០(ហាសិបលាន)រៀល និងមានដើមទុនតិចជាង ឬស្មើ២០.០០០.០០០(ម្ភៃលាន)រៀល

ង. មានបុគ្គលិកបម្រើការងារតិចជាង៤នាក់ និងមានទីតាំងទីស្នាក់ការដែលមានទំហំមិនលើសពី៣(បី)ម៉ែត្រការ៉េ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍

**ប្រការ៨ ._**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ការត្រួតពិនិត្យ វាយតម្លៃការផ្តល់ ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្នអាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ រួមទាំងសាខា។

ការធ្វើប្រតិភូកម្មមុខងារផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ រួមទាំងសាខា ឱ្យមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ៩ ._**

គ្មានបុគ្គលណាអាចប្រកបអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ រួមទាំងសាខាបានដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ដែលផ្តល់ដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

**ប្រការ១០ ._**

បុគ្គលដែលប្រកបអាជីវកម្មទេសចរណ៍ច្រើនប្រភេទនៅលើទីតាំងតែមួយ ប្រភេទអាជីវកម្មនីមួយៗត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍ផ្សេងៗគ្នា។

បុគ្គលដែលប្រកបអាជីវកម្មទេសចរណ៍មួយប្រភេទ ហើយមានសាខាច្រើនកន្លែង សាខានីមួយៗនោះត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍ផ្សេងៗគ្នា។

## ជំពូកទី៣
## វិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដល់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍

**ប្រការ១១ ._**

បុគ្គលដែលប្រកបអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ឬបើកសាខាត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ប្រព័ន្ធអនឡាញទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

ក. វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
ខ. លិខិតបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្មពីធនាគារដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍
គ. លិខិតបញ្ជាក់ទីស្នាក់ការ ឬកិច្ចសន្យាជួលផ្ទះដោយមានបញ្ជាក់ពីភូមិ ឬឃុំ/សង្កាត់
ឃ. កិច្ចសន្យារបស់ប្រត្តិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម
ង. អត្តសញ្ញាណបណ្ណសញ្ញាតិខ្មែរ ឬលិខិតឆ្លងដែន( សម្រាប់ជនបរទេស)
ច. រូបថតបច្ចុប្បន្នភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ទំហំ( ៤x៦ )ចំនួន៣សន្លឹក។

**ប្រការ១២ ._**

បុគ្គលដែលស្នើសុំបន្តអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ រួមទាំងសាខាត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធអនឡាញទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

ក. អាជ្ញាបណ្ណទេសចរណ៍(ថតចម្លង)

ខ. របាយការណ៍សកម្មភាពអាជីវកម្មឆ្នាំមុន

គ. កិច្ចសន្យារបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ក្នុងការប្រកបអាជីវកម្ម

ឃ. រូបថតបច្ចុប្បន្នភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ទំហំ(៤x៦)ចំនួន៣សន្លឹក។

**ប្រការ១៣ ._**

លក្ខខណ្ឌ និងបែបបទដើម្បីស្នើសុំអាជ្ញាបណ្ណការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ (ថ្មី បន្ត ឬបិទអាជីវកម្ម) ត្រូវបានកែសម្រួល និងបន្ថែមក្នុងករណី ដូចខាងក្រោម៖

ក. ករណីមានការផ្ទេរសិទ្ធិឈ្មោះ ឬប្តូរម្ចាស់អាជ្ញាបណ្ណទេសចរណ៍ អ្នកស្នើសុំអាជ្ញាបណ្ណការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ដែលជាអ្នកទទួលសិទ្ធិឈ្មោះ ឬម្ចាស់អាជ្ញាបណ្ណទេសចរណ៍នោះត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ១១ និងប្រការ១២ ដូចខាងក្រោម៖

១. លិខិតប្រគល់សិទ្ធិ

២. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់អ្នកផ្ទេរសិទ្ធិ (ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ចាស់ដែលត្រូវប្តូរ)

៣. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់អ្នកទទួលសិទ្ធិ (ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ថ្មី)

ខ. ករណីប្តូរនាមករណ៍ អ្នកស្នើសុំអាជ្ញាបណ្ណការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ១១ និងប្រការ១២ ដូចខាងក្រោម៖

១. លិខិតអនុញ្ញាតឲ្យប្តូរនាមករណ៍ថ្មីចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានីខេត្ត

២. កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ទទួលខុសត្រូវចំពោះនាមករណ៍ចាស់។

**ប្រការ១៤ ._**

បុគ្គលដែលប្រកបអាជីវកម្មភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) ឬមានសាខាត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍តាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធអនឡាញទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

ក. វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មពីមន្ទីរពាណិជ្ជកម្មរាជធានីខេត្ត ឬការិយាល័យច្រកចេញចូលតែមួយរបស់សាលារាជធានីខេត្ត

ខ. លិខិតបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្មពីធនាគារដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍

គ. កិច្ចសន្យារបស់ប្រត្តិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម

ឃ. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

ង. រូបថតបច្ចុប្បន្នភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ទំហំ(៤x៦)ចំនួន៣សន្លឹក។

**ប្រការ១៥ ._**

បុគ្គលដែលស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) រួមទាំងសាខា ត្រូវដាក់ពាក្យស្នើសុំពីក្រសួងទេសចរណ៍ តាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ប្រព័ន្ធអនឡាញទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួន ដូចខាងក្រោម៖

ក. អាជ្ញាបណ្ណទេសចរណ៍(ថតចម្លង)

ខ. កិច្ចសន្យារបស់ប្រត្តិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម

គ. រូបថតបច្ចុប្បន្នភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ទំហំ(៤x៦)ចំនួន៣សន្លឹក។

ករណីមានការផ្ទេរសិទ្ធិឈ្មោះ ឬប្តូរម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ឬប្តូរនាមករណ៍របស់ភ្នាក់ងារទេសចរណ៍ក្នុងស្រុកត្រូវអនុវត្តដូចចែងក្នុងប្រការ១៣នៃប្រកាសនេះ។

**ប្រការ១៦ ._**

ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិនឹងជូនដំណឹងទៅអ្នកស្នើសុំអំពីសេចក្តីសម្រេចឯកភាពផ្តល់ឲ្យ ឬមិនឯកភាពផ្តល់ឲ្យក្នុងរយៈពេល២៨(ម្ភៃប្រាំបី)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីអ្នកស្នើសុំបានបំពេញបែបបទត្រឹមត្រូវឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យ និងការតម្រូវដូចមានចែងក្នុងប្រកាសនេះ។

**ប្រការ១៧ ._**

អាជ្ញាបណ្ណទេសចរណ៍មានសុពលភាពរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណទេសចរណ៍ដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ១៨ ._**

ប្រសិនបើអ្នកស្នើសុំបានបំពេញបែបបទឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យ និងការតម្រូវនានាដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិនឹងចេញអាជ្ញាបណ្ណទេសចរណ៍ជូនអ្នកស្នើសុំមានសុពលភាពរយៈពេល០១(មួយ)ឆ្នាំ។ ក្នុងករណី អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពុំអាចបំពេញបែបបទឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យ និងការតម្រូវនានាដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចចេញអាជ្ញាបណ្ណបណ្តោះអាសន្នដែលមានសុពលភាពរយៈ៩០(កៅសិប)ថ្ងៃ ក្រោយពេលអ្នកស្នើសុំបានបង់កម្រៃអាជ្ញាបណ្ណទេសចរណ៍រួច ដោយតម្រូវឱ្យអ្នកស្នើសុំធ្វើកិច្ចសន្យាបំពេញបន្ថែមនូវលក្ខខណ្ឌដែលមិនពេញលេញជាលាយលក្ខណ៍អក្សរ។

ក្នុងរយៈពេលកំណត់នៃកិច្ចសន្យា បើម្ចាស់អាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្នបានបំពេញតាមលក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិនឹងផ្តល់អាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិដល់អ្នកស្នើសុំ។

ផ្ទុយទៅវិញក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញតាមលក្ខណវិនិច្ឆ័យនៃប្រកាសនេះ និងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា អាជ្ញាបណ្ណបណ្តោះអាសន្នដែលចេញដោយក្រសួងទេសចរណ៍ ឬ

មន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិអស់សុពលភាពនឹងត្រូវចាត់ទុកថាជាការធ្វើអាជីវ-កម្មដោយគ្មានអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ១៩ ._**

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ត្រូវដាក់ពាក្យសុំបន្តអាជ្ញាបណ្ណទេសចរណ៍ឲ្យបាន៣០(សាមសិប)ថ្ងៃ យ៉ាងតិច មុនថ្ងៃផុតកំណត់នៃសុពលភាពអាជ្ញាបណ្ណទេសចរណ៍ចាស់។

ក្នុងករណីដែលម្ចាស់អាជ្ញាបណ្ណទេសចរណ៍នៅតែបន្តអាជីវកម្មលើអាជ្ញាបណ្ណទេសចរណ៍ដែលអស់សុពលភាពនឹងត្រូវចាត់ទុកថាជាការធ្វើអាជីវកម្មទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ២០ ._**

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍អាចធ្វើការផ្ទេរ ឬលក់អាជ្ញាបណ្ណទេសចរណ៍របស់ខ្លួនបាន ដោយត្រូវដាក់ពាក្យស្នើសុំមកក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការផ្ទេរ ឬលក់អាជ្ញាបណ្ណទេសចរណ៍អាចប្រព្រឹត្តទៅបានដោយអនុវត្តតាមលក្ខខណ្ឌ ដែលមានចែងក្នុងវាក្យខ័ណ្ឌទី២នៃមាត្រា៤៣ នៃច្បាប់ស្តីពីទេសចរណ៍។

**ប្រការ២១ ._**

ប្រតិបត្តិករទេសចរណ៍អាចដាក់ពាក្យស្នើសុំព្យួរអាជ្ញាបណ្ណទេសចរណ៍របស់ខ្លួន ជាបណ្តោះអាសន្នបានក្នុងរយៈពេល០១ឆ្នាំ ការស្នើសុំនេះមិនត្រូវលើសពី០២ ដោយមានការយល់ព្រមពីក្រសួងទេសចរណ៍ និង/ឬមន្ទីរទេសចរណ៍រាជធានីខេត្ត និង/ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៤
## លក្ខខណ្ឌនៃការប្រើប្រាស់អាជ្ញាបណ្ណទេសចរណ៍របស់ប្រតិបត្តិករទេសចរណ៍

**ប្រការ២២ ._**

ម្ចាស់អាជ្ញាបណ្ណការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ព្រមទាំងសាខាត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

ក. ត្រូវប្រើប្រាស់អាជ្ញាបណ្ណទេសចរណ៍ឲ្យបានត្រឹមត្រូវ ស្របតាមកម្មវត្ថុនៃអាជីវកម្មរបស់ខ្លួន និងត្រូវគោរពច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងអនុវត្តតាមការណែនាំនានារបស់ក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ។

ខ. មិនត្រូវបានអនុញ្ញាតឲ្យបុគ្គល ឬការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ឬសាខាដទៃប្រើប្រាស់នាមករណ៍អាជ្ញាបណ្ណរបស់ខ្លួនឡើយ។

គ. មិនត្រូវបានអនុញ្ញាតឲ្យធ្វើប្រតិបត្តិការឈរឈ្មោះតំណាងឲ្យការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ ឬសាខាដទៃ ក្រៅពីការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ និងសាខារបស់ខ្លួនឡើយ។

ឃ. ត្រូវដាក់តាំងអាជ្ញាបណ្ណទេសចរណ៍នៅកន្លែងទទួលភ្ញៀវដែលងាយមើលឃើញច្បាស់។

ង. ក្នុងករណីមានការខូចខាត ឬបាត់បង់អាជ្ញាបណ្ណទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្នើសុំអាជ្ញាបណ្ណទសចរណ៍ទុតិយតាក្នុងរយៈពេល៣០(សាបសិប)ថ្ងៃ គិតពីថ្ងៃដែលខូចខាត ឬបាត់បង់។

# ជំពូកទី៥
# ប្រាក់តម្កល់ និងកម្រៃអាជ្ញាបណ្ណទេសចរណ៍សម្រាប់
# ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍

**ប្រការ២៣ ._**

ប្រាក់តម្កល់ជានាអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ត្រូវបានកំណត់ទៅតាមវិសាលភាពនិងទំហំអាជីវកម្ម ដូចខាងក្រោម ៖

ក. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ការីទេសចរណ៍ ដែលអាចធ្វើអាជីវកម្មរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Inbound Tour Operators) ត្រូវតម្កល់ប្រាក់ជានាអាជីវកម្មចំនួន៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក។

ខ. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ការីទេសចរណ៍ ដែលអាចធ្វើអាជីវកម្មរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា (Outbound Tour Operators) ត្រូវតម្កល់ប្រាក់ជានាអាជីវកម្មចំនួន៧.០០០(ប្រាំពីរពាន់)ដុល្លារអាមេរិក។

គ. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ភ្នាក់ងារទេសចរណ៍ (Travel Agent) ត្រូវតម្កល់ប្រាក់ជានាអាជីវកម្មចំនួន៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក។

ឃ. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ការីទេសចរណ៍ ដែលអាចធ្វើអាជីវកម្មរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវដែលមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា កម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Domestic Tour Operators) ត្រូវតម្កល់ប្រាក់ជានាអាជីវកម្មចំនួន២.០០០(ពីរពាន់)ដុល្លារអាមេរិក។

ង. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) ត្រូវតម្កល់ប្រាក់ជានាអាជីវកម្មចំនួន៥០០(ប្រាំរយ)ដុល្លារអាមេរិក។

ច. ចំពោះប្រត្តិបត្តិករទេសចរណ៍ ដែលមានអាជ្ញាបណ្ណទេសចរណ៍ជាការីទេសចរណ៍ច្រើនប្រភេទ រួមមាន អាជ្ញាបណ្ណជាការីទេសចរណ៍ផង និងភ្នាក់ងារទេសចរណ៍ផង ហើយស្ថិតក្រោមឈ្មោះតែមួយត្រូវតម្កល់ប្រាក់ក្នុងកម្រិតទឹកប្រាក់ខ្ពស់ជាងគេ។

ជ. សាខាមិនត្រូវឱ្យតម្កល់ប្រាក់ជានាអាជីវកម្មដោយឡែកឡើយ ក្នុងករណីដែលការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍(ស្នាក់ការកណ្តាល) របស់ខ្លួនបានអនុវត្តនីតិវិធីនៃការដាក់ប្រាក់តម្កល់ជានាអាជីវកម្មរួចរាល់ហើយ។

ក្រសួងទេសចរណ៍ទទួលបន្ទុកគ្រប់គ្រងលើប្រាក់តម្កល់ជានាអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍។

**ប្រការ២៤ ._**

ប្រតិបត្តិករទេសចរណ៍អាចដាក់ពាក្យសុំដកប្រាក់តម្កល់ជានាអាជីវកម្មរបស់ខ្លួនមកវិញបាន នៅពេលបិទអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍។ ក្នុងករណីនេះ ប្រត្តិបត្តិករទេសចរណ៍ត្រូវបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ និងធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈជាមុនក្នុងរយៈពេល៣០(សាមសិប)ថ្ងៃមុនថ្ងៃបិទអាជីវកម្មរបស់ខ្លួន។

ការបិទអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ត្រូវបានអនុញ្ញាត ក្នុងករណីដែលការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ដំណើរការអាជីវកម្មបានយ៉ាងហោចណាស់៩០ថ្ងៃ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណទេសចរណ៍។

ប្រត្តិបត្តិករទេសចរណ៍ដែលជាម្ចាស់អាជីវកម្មត្រូវធ្វើកិច្ចសន្យាជានា និងទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងករណីមានការពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុជាមួយនឹងដៃគូផ្សេងៗរបស់ខ្លួនកន្លងមក។ ក្រសួងទេសចរណ៍នឹងពិនិត្យសម្រេចអនុញ្ញាតលើការបិទអាជីវកម្ម ក្នុងរយៈពេលមិនលើសពី២៨(ម្ភៃប្រាំបី)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំពេញលេញ។

**ប្រការ២៥ ._**

កម្រៃអាជ្ញាបណ្ណទេសចរណ៍ ឬការអនុញ្ញាឱ្យបន្តអាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ត្រូវអនុលោមតាមប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងទេសចរណ៍។

## ជំពូកទី៦
## ភាតព្វកិច្ចរបស់ប្រតិបត្តិករទេសចរណ៍

**ប្រការ២៦ ._**

ប្រតិបត្តិករទេសចរណ៍ត្រូវមានកាតព្វកិច្ចដែលមានចែងក្នុងមាត្រា៤៨ នៃច្បាប់ស្តីពីទេសចរណ៍ និងអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ដែលរៀបចំដោយក្រសួងទេសចរណ៍ ឬសមាគមឧស្សាហកម្មទេសចរណ៍ ឬអង្គការទេសចរណ៍ពិភពលោកឲ្យបានល្អ។

**ប្រការ២៧ ._**

ប្រតិបត្តិករទេសចរណ៍ត្រូវមានផែនការ និងមានសកម្មភាពបណ្តុះបណ្តាល និងហ្វឹកហ្វឺនដល់បុគ្គលិកបម្រើការងារអំពីជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ស្របតាមការណែនាំរបស់ក្រសួងទេសចរណ៍។

**ប្រការ២៨ ._**

ប្រតិបត្តិករទេសចរណ៍ត្រូវផ្តល់របាយការណ៍ និងស្ថិតិពីអាជីវកម្មរបស់ខ្លួនជូនក្រសួងទេសចរណ៍រៀងរាល់០៣ខែម្តង និងទៅតាមការស្នើសុំរបស់ក្រសួងទេសចរណ៍។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**ប្រការ២៩ ._**

ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ រួមទាំងសាខា ដែលប្រកបអាជីវកម្មដោយប្រើប្រាស់អាជ្ញាបណ្ណទេសចរណ៍ហួសសុពលភាព ឬប្រព្រឹត្តខុសក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈការី-ទេសចរណ៍និងភ្នាក់ងារទេសចរណ៍ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់អនុលោមតាមប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងទេសចរណ៍។

**ប្រការ៣០ ._**

ជនណាដែលក្លែងអាជ្ញាបណ្ណការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ឬឯកសារសាធារណៈផ្សេងៗ ត្រូវផ្តន្ទាទោសតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ៣១ ._**

ប្រកាសលេខ០៤១ ប្រក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដល់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣២ ._**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣៣ ._**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គាធិការ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ និងប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីខេត្ត
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)
- សមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា (PATA)
- ដូចប្រការ៣៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ